ក្រសួងអប់រំ យុវជន និងកីឡា

---

វិទ្យាស្ថានជាតិអប់រំ

# កម្មវិធីបណ្តុះបណ្តាល
# បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

---

ឆ្នាំសិក្សា ខែតុលា ឆ្នាំ២០១២

មាតិកា

**ទំព័រ**

អារម្ភកថា....................................................................................................ii
១. សារតា.......................................................................................................១
២. ការពិពណ៌នាកម្មវិធីបណ្តុះបណ្តាល...................................................................១
៣. ចក្ខុវិស័យ...................................................................................................១
៤. បេសកកម្ម...................................................................................................២
៥. រចនាសម្ព័ន្ធកម្មវិធីបណ្តុះបណ្តាល....................................................................២
៥.១ លក្ខណសម្បត្តិដើម្បីទទួលសញ្ញាបត្រ.......................................................២
៥.២ មុខវិជ្ជាសិក្សា............................................................................................២
៥.៣ ការកំណត់ និងការវាយតម្លៃដើម្បីផ្ទេរក្រេឌីត...............................................៣
៥.៤ ចំណាត់ថ្នាក់ពិន្ទុ(GPA).................................................................................៤
៦. ការពិពណ៌នាអំពីមុខវិជ្ជាសិក្សា.........................................................................៤
៧. លក្ខណសម្បត្តិរបស់សាស្ត្រាចារ្យ និងសមាជិកមហាវិទ្យាល័យ...................................១០
៨. លក្ខខណ្ឌនៃការជ្រើសរើសបេក្ខជន....................................................................១១
៩. ពេលវេលាសិក្សា...........................................................................................១១
៩.១ វគ្គសិក្សាក្រៅម៉ោងធ្វើការ(វគ្គពិសេស).......................................................១១
៩.២ វគ្គសិក្សានៅចុងសប្តាហ៍(វគ្គទៀងទាត់)........................................................១១

# អារម្ភកថា

សង្គតិភាពក្នុងការគ្រប់គ្រង ជាកត្តាដ៏ចម្បងក្នុងការលើកកម្ពស់គុណភាពអប់រំ ដែលក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសមន្ត្រីគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ បាននិងកំពុងយកចិត្តទុកដាក់ជាទីបំផុត។

អនុវត្តតាមផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣ និងដើម្បីសមាហរណកម្មអាស៊ានឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយដៃគូអភិវឌ្ឍន៍ មូលនិធិគាំទ្រអប់រំអន្តរជាតិ (CIESF) រៀបចំកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនេះឡើងនៅវិទ្យាស្ថានជាតិអប់រំ។

កម្មវិធីនេះ រៀបចំឡើងក្នុងគោលបំណងបណ្តុះបណ្តាលផ្នែកគ្រប់គ្រងអប់រំ ដល់មន្ត្រី និងបុគ្គលិក ដែលកំពុងបម្រើការងារនៅតាមស្ថាប័នអប់រំនានា និងដើម្បីលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពការងារគ្រប់គ្រង ការដឹកនាំ សំដៅធានា និងសម្រេចបានគោលដៅអប់រំ ឱ្យទទួលបានជោគជ័យ។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះក្រុមការងារ និងមូលនិធិគាំទ្រអប់រំអន្តរជាតិ (CIESF) ដែលបានយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត និងបញ្ញាស្មារតី ក្នុងការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលដ៏មានសារៈសំខាន់នេះ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ២០១២

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

អ៊ឹម_សិទ្ធី

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជា ធ្លាប់មានអរិយធម៌ឧត្តុង្គឧត្តម និងកិត្យានុភាពខ្ពង់ខ្ពស់។ ក្នុងទសវត្សឆ្នាំ១៩៥០ និងឆ្នាំ១៩៦០ ប្រទេសកម្ពុជាមានការអភិវឌ្ឍទាំងផ្នែកសង្គម និងសេដ្ឋកិច្ច ហើយវិស័យអប់រំត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងតំបន់ និងនៅលើពិភពលោក។ ក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ កម្ពុជាបានឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយទ្រុឌទ្រោមគួរឱ្យសោកស្តាយ។ នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ប្រព័ន្ធអប់រំត្រូវបានគេបោះបង់ និងលុបបំបាត់ចោលទាំងស្រុង ហើយគ្រូបង្រៀនប្រមាណ៨០ភាគរយត្រូវបានកាប់សម្លាប់ធ្វើឱ្យប្រទេសកម្ពុជាបាត់បង់ធនធានមនុស្សយ៉ាងច្រើន។

ស្ថិតក្នុងបរិបទនេះ ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំស្តារ និងអភិវឌ្ឍវិស័យអប់រំធ្វើឱ្យវិស័យនេះមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ទន្ទឹមនឹងនេះ ក្រសួងក៏បានកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣ដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ សំដៅអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជា។ គោលនយោបាយ និងយុទ្ធសាស្ត្រដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ត្រូវបានអនុវត្តក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ ក្រសួងលើកទឹកចិត្តឱ្យវិទ្យាស្ថានជាតិអប់រំ បើកវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ដោយមានការជួយឧបត្ថម្ភទាំងផ្នែកបច្ចេកទេស សម្ភារៈ និងថវិកាពីមូលនិធិគាំទ្រវិស័យអប់រំនៅកម្ពុជា។ ការបើកវគ្គបណ្តុះបណ្តាលនេះនឹងជួយឱ្យមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់ ដែលកំពុងធ្វើការក្នុងវិស័យអប់រំ មានឱកាសលើកកម្ពស់សមត្ថភាពក្នុងការបំពេញការងារ។

## ២. ការពិពណ៌នាកម្មវិធីបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ត្រូវបានបង្កើតឡើងសម្រាប់បណ្តុះបណ្តាលធនធានមនុស្ស លើការងាររដ្ឋបាលអប់រំ ផែនការកម្មអប់រំ ការគ្រប់គ្រងអប់រំ និងភាពជាអ្នកដឹកនាំ ព្រមទាំងក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីក្លាយជាអ្នករដ្ឋបាល អ្នកធ្វើផែនការ អ្នកគ្រប់គ្រង និងអ្នកដែលមានតួនាទីផ្នែករដ្ឋបាលផ្សេងៗទៀត។

## ៣. ចក្ខុវិស័យ

ចក្ខុវិស័យនៃកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ គឺបណ្តុះបណ្តាលអ្នកសិក្សាឱ្យមានចំណេះដឹង និងជំនាញ ដែលមានកម្រិតប្រហាក់ប្រហែលនឹងថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីរួមចំណែកអភិវឌ្ឍសង្គមពុទ្ធិប្រកបដោយនិរន្តរភាព។

## ៤.បេសកកម្ម

បេសកកម្មនៃកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ គឺរៀបចំកម្មវិធីបណ្តុះបណ្តាល ជ្រើសរើសសាស្ត្រាចារ្យដែលមានគុណវុឌ្ឍិ ជ្រើសរើសសិក្ខាកាមដែលមានលក្ខណសម្បត្តិសមស្រប និងតាក់តែងឯកសារប្រកបដោយគុណភាពដើម្បីសម្រេចចក្ខុវិស័យខាងលើ។

## ៥. រចនាសម្ព័ន្ធកម្មវិធីបណ្តុះបណ្តាល

### ៥.១ លក្ខណសម្បត្តិ ដើម្បីទទួលសញ្ញាបត្រ

កម្មវិធីសិក្សានេះមាន៤៨ ក្រេឌីត (សិក្សារយៈពេល២ ឆ្នាំ) ដែលក្នុងនោះមានៈ

ក-មុខវិជ្ជាមូលដ្ឋានរៀបចំឡើងដើម្បីកសាងមូលដ្ឋានគ្រឹះនៃការអប់រំឱ្យរឹងមាំ និងដើម្បីអភិវឌ្ឍជំនាញក្នុងការស្រាវជ្រាវ មាន១៥ ក្រេឌីត (ស្មើ៥ មុខវិជ្ជា)។

ខ-មុខវិជ្ជាជំនាញវិជ្ជាជីវៈ រៀបចំឡើងក្នុងគោលបំណងធានាជំនាញឯកទេសនីមួយៗ មាន២៤ ក្រេឌីត (ស្មើ៨ មុខវិជ្ជា)។

គ-មុខវិជ្ជាជ្រើសរើសរៀបចំឡើងក្នុងគោលបំណងឱ្យមានចំណេះដឹងទូលំទូលាយ និងមានជំនាញផ្សេងទៀត មាន៣ក្រេឌីត (ស្មើ១ មុខវិជ្ជា)។

ឃ-ពេលបញ្ចប់ការសិក្សា អ្នកសិក្សាត្រូវសរសេរនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដែលមាន៦ ក្រេឌីត។ ការសរសេរនេះគឺដើម្បីពង្រឹងជំនាញរបស់អ្នកសិក្សាឱ្យមានសមត្ថភាពក្នុងការស្រាវជ្រាវលើប្រធានបទជាក់លាក់ណាមួយ។

### ៥.២ មុខវិជ្ជាសិក្សា

| កម្មវិធីសិក្សា | លេខកូដ | អាទិភាព | ចំនួនក្រេឌីត |
|---|---|---|---|
| **I. មុខវិជ្ជាមូលដ្ឋាន** | | | |
| ១. ក្រមសីលធម៌អ្នកដឹកនាំអប់រំ | MEA 510 | ចាំបាច់ | ៣ |
| ២. ចិត្តវិទ្យាអប់រំ | MEA 511 | ចាំបាច់ | ៣ |
| ៣. សង្គមវិទ្យាអប់រំ | MEA 512 | ចាំបាច់ | ៣ |
| ៤. ស្ថិតិអប់រំ | MEA 513 | ចាំបាច់ | ៣ |
| ៥. វិធីសាស្ត្រស្រាវជ្រាវអប់រំ | MEA 514 | ចាំបាច់ | ៣ |
| | | សរុប | **១៥** |
| **II. មុខវិជ្ជាជំនាញ** | | | |
| ១. ការអប់រំនៅកម្ពុជា: ប្រវត្តិ រចនាសម្ព័ន្ធ និងការគ្រប់គ្រង | MEA 520 | ចាំបាច់ | ៣ |
| ២.ការអប់រំ និងគោលនយោបាយអប់រំ: វិភាគប្រៀបធៀប | MEA 521 | ចាំបាច់ | ៣ |

| | | | |
|---|---|---|---|
| លើស្ថានភាពបច្ចុប្បន្ន និងនិន្នាការនៅពេលអនាគត | | | |
| ៣. រដ្ឋបាលអប់រំ: ការកសាងផែនការ និងការអនុវត្តផែនការ | MEA 522 | ចាំបាច់ | ៣ |
| ៤. ការគ្រប់គ្រងការបង្រៀន និងបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំ | MEA 523 | ចាំបាច់ | ៣ |
| ៥. ការអភិវឌ្ឍកម្មវិធីសិក្សា | MEA 524 | ចាំបាច់ | ៣ |
| ៦. ការគ្រប់គ្រងសម្ភារៈ និងថវិកាវិស័យអប់រំ | MEA 525 | ចាំបាច់ | ៣ |
| ៧. ការគ្រប់គ្រងធនធានមនុស្ស | MEA 526 | ចាំបាច់ | ៣ |
| ៨. ការពិនិត្យតាមដាន និងវាយតម្លៃអប់រំ | MEA 527 | ចាំបាច់ | ៣ |
| | | សរុប | **២៤** |
| III. មុខវិជ្ជាជ្រើសរើស (ជ្រើសរើស១ មុខវិជ្ជា ក្នុងចំណោម២ មុខវិជ្ជា) | | | |
| ១. ការគ្រប់គ្រងការបំពេញការងារក្នុងសាលា | MEA 530 | ជម្រើស | ៣ |
| ២. ការគ្រប់គ្រងរដ្ឋបាលអប់រំនៅគ្រឹះស្ថានសិក្សាឯកជន | MEA 531 | ជម្រើស | ៣ |
| | | សរុប | **៣** |
| IV. ការបញ្ចប់ការសិក្សា (និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់) | | | |
| ១. និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | MEA 599 | ចាំបាច់ | ៦ |
| | | [illegible] | [illegible] |

## ៥.៣ ការកំណត់ និងការវាយតម្លៃ ដើម្បីផ្ទេរក្រេឌីត

- អ្នកសិក្សាអាចផ្ទេរចំនួនក្រេឌីត ដើម្បីអាចទទួលសញ្ញាបត្របាន។
- អ្នកសិក្សា ដែលមានបទពិសោធច្រើន ឬធ្លាប់សិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ អាចដាក់ពាក្យសុំផ្ទេរក្រេឌីតបាន។
- ការផ្ទេរក្រេឌីតអាចផ្តល់ឱ្យអ្នកសិក្សាណា ដែលបានដាក់ពាក្យសុំតែប៉ុណ្ណោះ ហើយគេអាចផ្ទេរបានយ៉ាងច្រើនបំផុតត្រឹមតែ៩ ក្រេឌីត (ស្មើ៣ មុខវិជ្ជា) ក្នុងចំណោម៤៨ ក្រេឌីត។
- អ្នកសិក្សាត្រូវតែដាក់ច្បាប់ចម្លងនៃកម្មវិធីសង្ខេបដោយភ្ជាប់ជាមួយនឹងព្រឹត្តិបត្រពិន្ទុសម្រាប់មុខវិជ្ជាសិក្សាណាដែលគេស្វែងរកការសុំជំនួស ឬផ្ទេរក្រេឌីត ។

៥.៤ ចំណាត់ថ្នាក់ពិន្ទុ(GPA)

| ពិន្ទុតាមកម្រិត | សមាសភាគភាគរយ | សញ្ញាពិន្ទុជាអក្សរ | ការបរិយាយ |
|---|---|---|---|
| ៤.០០ | ៩៦-១០០ | A+ | ល្អឥតខ្ចោះ |
| ៣.៦៧ | ៩០-៩៥ | A | ល្អប្រសើរណាស់ |
| ៣.៣៣ | ៨៦-៨៩ | A- | ល្អប្រសើរ |
| ៣.០០ | ៨៣-៨៥ | B+ | ល្អណាស់ |
| ២.៦៧ | ៨០-៨២ | B | ល្អ |
| ២.៣៣ | ៧៦-៧៩ | B- | ល្អបង្គួរ |
| ២.០០ | ៧១-៧៥ | C+ | លើមធ្យម |
| ១.៦៧ | ៦៦-៧០ | C | មធ្យម |
| ១.០០ | ៦០-៦៥ | C- | ធ្លាក់ |

## ៦. ការពិពណ៌នាអំពីមុខវិជ្ជាសិក្សា

### MEA 510 ក្រមសីលធម៌អ្នកដឹកនាំអប់រំ

មុខវិជ្ជានេះនឹងសិក្សាពីបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងក្រមសីលធម៌អ្នកដឹកនាំអប់រំ។ អ្នកសិក្សានឹងត្រូវលើកទឹកចិត្តឱ្យធ្វើការពិចារណាពីក្រមសីលធម៌ និងបង្កើតការវាយតម្លៃផ្ទាល់ខ្លួនលើក្រមសីលធម៌ទាំងនោះ។ លើសពីនេះទៀត ទស្សនៈស្តីពីការអភិវឌ្ឍជំនាញអប់រំបន្តនឹងត្រូវលើកយកមកសិក្សាស្រាវជ្រាវផងដែរ។ គោលដៅនៃមុខវិជ្ជានេះនឹងប្រកាន់ខ្ជាប់នូវគន្លងអភិវឌ្ឍការអប់រំពេញមួយជីវិត។

### MEA 511 ចិត្តវិទ្យា អប់រំ

មូលដ្ឋានគ្រឹះនៃចិត្តវិទ្យាអប់រំ និងការស្វែងរកទ្រឹស្តីអនុវត្តន៍ជាក់ស្តែង នៃចិត្តវិទ្យាអប់រំ នឹងត្រូវលើកយកមកសិក្សានៅក្នុងមុខវិជ្ជានេះ។ របៀបនៃការសិក្សា កត្តាដែលអាចធ្វើឱ្យប៉ះពាល់ដល់ដំណើរការនៃការសិក្សា និងឥទ្ធិពលនៃវប្បធម៌ទៅលើការសិក្សាក៏នឹងត្រូវបានលើកមកពិភាក្សាផងដែរ។ អ្នកសិក្សាត្រូវបានលើកទឹកចិត្តឱ្យពិភាក្សា និងអភិវឌ្ឍនូវទ្រឹស្តីផ្ទាល់ខ្លួនទៅលើទិដ្ឋភាពនៃចិត្តវិទ្យាអប់រំ។

### MEA 512 សង្គមវិទ្យាអប់រំ

មុខវិជ្ជានេះ នឹងផ្តោតទៅលើការបង្កើត និងអនុវត្តបញ្ញត្តិរបស់សង្គម រួមនឹងទស្សនវិស័យ

ដែលពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួនដូចជា ការសិក្សា និងសង្គម វប្បធម៌យុវជន យែនឌ័រ ក្នុងការអប់រំ ដំណើរការជ្រើសរើសសិស្សឱ្យចូលសាលារៀន ការងារ និងការសិក្សា ការបែងចែកវណ្ណៈ និងសង្គម។

## MEA 513 ស្ថិតិអប់រំ

មុខវិជ្ជានេះ នឹងរំឭកឡើងវិញនូវបញ្ញត្តិសំខាន់ៗនៃគណិតវិទ្យា ទ្រឹស្តីគន្លឹះនៃស្ថិតិ និងការប្រើប្រាស់កុំព្យូទ័រ។ ស្ថិតិពិពណ៌នា ការគណនាពិន្ទុ សំណាកគំរូ ប្រូបាប តម្រែតម្រង់លីនេអ៊ែ ការណែនាំពីស្ថិតិសន្និដ្ឋាន និងតេស្តនៃសារសំខាន់ជាមូលដ្ឋាននឹងត្រូវលើកយកមកពិភាក្សានៅក្នុងមុខវិជ្ជានេះ។

## MEA 514 វិធីសាស្ត្រស្រាវជ្រាវអប់រំ

មុខវិជ្ជានេះ បង្កើតឡើងដើម្បីលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពអ្នកសិក្សាដែលមានបំណងក្នុងការសរសេររបាយការណ៍ស្រាវជ្រាវឱ្យមានភាពសុក្រឹត តាមរយៈការរំឭកឡើងវិញពីវេយ្យាករណ៍ និងជំនាញក្នុងការសរសេរ។ មុខវិជ្ជានេះក៏ផ្តោតផងដែរលើមូលដ្ឋានគ្រឹះនៃវិធីសាស្ត្រស្រាវជ្រាវអប់រំដែលរួមមានការស្រាវជ្រាវតាមបែបគុណភាព និងបរិមាណការជ្រើសរើសសំណាកគំរូ ក្រមសីលធម៌ ឧបករណ៍ស្រាវជ្រាវ និងលទ្ធផលអាចយកជាការបាន ក្នុងគោលបំណងដើម្បីបង្កើនសមត្ថភាពវិភាគត្រិះរិះពិចារណា និងដើម្បីពង្រឹងយុទ្ធសាស្ត្រឱ្យទទួលបានលទ្ធផលល្អប្រសើរក្នុងការអប់រំ។ ការកំណត់ និងការវាយតម្លៃទៅលើបញ្ហាស្រាវជ្រាវ ការប្រើប្រាស់ធនធានបណ្ណាល័យ ការប្រមូលទិន្នន័យ និងការសរសេររបាយការណ៍ស្រាវជ្រាវជាចំណុចសំខាន់ក្នុងមុខវិជ្ជានេះ។

## MEA 520 ការអប់រំនៅកម្ពុជា: ប្រវត្តិ រចនាសម្ព័ន្ធ និងការគ្រប់គ្រង

មុខវិជ្ជានេះ អ្នកសិក្សានឹងត្រូវបានលើកទឹកចិត្តឱ្យពិនិត្យ និងពិភាក្សាពីប្រព័ន្ធអប់រំកម្ពុជារួមជាមួយនឹងការអភិវឌ្ឍសង្គមនៅសម័យមុន ដោយផ្តោតទៅលើមនោគមវិជ្ជា ទស្សនវិជ្ជា និងប្រវត្តិនៃការអប់រំក្នុងអតីតកាលចាប់ពីសម័យអាណានិគមនិយមបារាំង រហូតមកដល់ពេលបច្ចុប្បន្ន។ មុខវិជ្ជានេះ នឹងលើកយកមកពិភាក្សាផងដែរពីប្រព័ន្ធ និងការគ្រប់គ្រងអប់រំនាពេលបច្ចុប្បន្នរបស់កម្ពុជាចាប់ពីមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សារួមមានសេចក្តីណែនាំ លក្ខណៈវិនិច្ឆ័យ និងលំនាំនៃការវាយតម្លៃដែលបង្កើតឡើងដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ។ ជាងនេះទៅទៀត ស្ថានភាព និងនិន្នាការនៃការអប់រំនៅអតីតកាល និងនៅពេលបច្ចុប្បន្ន ក៏ដូចជាឥទ្ធិពល និងផលប៉ះពាល់នៃសង្គមត្រូវបានគេលើកយកមកសិក្សានិងធ្វើការប្រៀបធៀបផងដែរ។

**MEA 521 ការអប់រំ និងគោលនយោបាយអប់រំៈ វិភាគប្រៀបធៀបលើស្ថានភាពបច្ចុប្បន្ន និងនិន្នាការនៅពេលអនាគត**

មុខវិជ្ជានេះ លើកយកបញ្ហាសំខាន់ៗ និងបញ្ហាប្រឈមមួយចំនួនក្នុងផ្នែកគ្រប់គ្រងអប់រំនៅក្នុងសង្គម និងវប្បធម៌នៃប្រទេសដទៃមកពិភាក្សា និងធ្វើការប្រៀបធៀប។ នីតិរដ្ឋប្បវេណី នីតិរដ្ឋបាល និងច្បាប់ផ្សេងៗដែលទាក់ទងនឹងវិស័យអប់រំក៏ត្រូវបានលើកយកមកពិភាក្សានៅក្នុងមុខវិជ្ជានេះផងដែរ។ ជាងនេះទៅទៀត បញ្ហា និងនិន្នាការក្នុងការអប់រំនាពេលបច្ចុប្បន្នដូចជានយោបាយ ទ្រឹស្តី និងការអនុវត្តនៅក្នុងបរិបទនៃសតវត្សទី២១ក៏ត្រូវបានសំយោគឡើង។

**MEA 522 រដ្ឋបាលអប់រំៈ ការកសាងផែនការ និងការអនុវត្តផែនការ**

មុខវិជ្ជានេះ ផ្តោតជាពិសេសទៅលើវិធីសាស្ត្រក្នុងការវិភាគស្ថានភាពរបស់អង្គភាពឬប្រព័ន្ធច្បាស់លាស់មួយ ដើម្បីបង្កើតយុទ្ធសាស្ត្រ និងគោលនយោបាយឱ្យបានសមស្រប។ ជាងនេះទៅទៀតគឺផ្តោតទៅលើការប្រើប្រាស់វិធីសាស្ត្រផ្សេងៗដើម្បីរៀបចំគម្រោង និងរបៀបរៀបចំគម្រោងដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទាំងនោះតាមបែបមជ្ឈការនិងវិមជ្ឈការ ។ វិធីសាស្ត្រក្នុងការគ្រប់គ្រង និងរៀបចំផែនការកម្មវិធី ផ្អែកលើលទ្ធផល នឹងត្រូវដាក់បញ្ចូលនៅក្នុងមុខវិជ្ជានេះដោយប្រើប្រាស់ការសិក្សាផ្អែកលើ ការពិសោធជាក់ស្តែង រួមបញ្ចូលវិធីសាស្ត្រវិភាគធម្មតា វិធីសាស្ត្រដោះស្រាយបញ្ហា ការជ្រើសរើសយុទ្ធសាស្ត្រ និងការលើកគម្រោងត្រឹមត្រូវ។ ក្រៅពីនេះក៏ណែនាំអំពីវិធីសាស្ត្រ លើកគម្រោងផ្អែកលើការអប់រំសិទ្ធមនុស្ស ដោយរួមបញ្ចូលនូវគោលការណ៍សិទ្ធិសម្រាប់ការអប់រំ ការវិភាគតួនាទីគំរូ និងការវិភាគអំពីគម្លាតនៃសមត្ថភាព។ ផ្តល់ឱ្យអ្នកសិក្សានូវព័ត៌មានសំខាន់ៗ និងចាំបាច់ដែលទាក់ទងទៅនឹងហិរញ្ញប្បទានវិស័យអប់រំ។ មុខវិជ្ជានេះ ក៏ផ្តោតជាសំខាន់ទៅលើមេរៀនដូចជាសាលារៀនជាប្រព័ន្ធនៃសង្គមមួយ បច្ចេកទេសស្នូលក្នុងការរៀន និងបង្រៀន រចនាសម្ព័ន្ធសាលារៀន តួនាទីបុគ្គលក្នុងសាលារៀន វប្បធម៌ និងបរិយាកាសរបស់សាលារៀន អំណាច និងគោលការណ៍នៅក្នុងសាលារៀន បរិស្ថានខាងក្រៅសាលារៀន ប្រសិទ្ធភាព និងគុណភាពសាលារៀន ការធ្វើសេចក្តីសម្រេចចិត្តក្នុងសាលារៀន ទំនាក់ទំនងក្នុងសាលារៀន និងភាពជាអ្នកដឹកនាំក្នុងសាលារៀន។

**MEA 523 ការគ្រប់គ្រងការបង្រៀន និងបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំ**

ការបង្កើតបរិយាកាសសិក្សា និងការបង្រៀនជោគជ័យសម្រាប់សិស្ស និងបុគ្គលិក គឺជាប្រធានបទយ៉ាងសំខាន់នៅក្នុងមុខវិជ្ជានេះ។ មុខវិជ្ជានេះត្រូវបានរៀបចំឡើងដើម្បីគ្រូ

ពិនិត្យលើការគ្រប់គ្រងការបង្រៀន បច្ចេកទេសក្នុងការរៀបចំ និងជំនាញផ្សេងៗទៀតដែលចាំបាច់ក្នុងការចាត់ចែង និងវាយតម្លៃកម្មវិធីបណ្តុះបណ្តាល។ មុខវិជ្ជានេះផ្តោតផងដែរលើវិធីសាស្ត្រសំខាន់ៗនៃការគ្រប់គ្រងបុគ្គលិក ការអភិវឌ្ឍកម្មវិធីសិក្សា ការលើកកម្ពស់ការបង្រៀនតាមរយៈការប្រមូលទិន្នន័យ ការវាយតម្លៃជាដំណាក់ ការវាយតម្លៃបញ្ចប់លើស្តង់ដារនៃការបង្រៀន និងការអភិវឌ្ឍបុគ្គលិក។ អ្នកសិក្សានឹងមានទំនាក់ទំនងល្អជាមួយបុគ្គលិក និងសហគមន៍ព្រោះពួកគេជាអ្នកបង្កើតស្តង់ដារសិស្ស វាយតម្លៃសិស្ស ជួយបុគ្គលិកក្នុងការវាយតម្លៃការសិក្សា ដឹកនាំការបង្រៀនឱ្យមានប្រសិទ្ធភាព និងលើកកម្ពស់បរិយាកាសសាលារៀនមួយសម្រាប់ការសិក្សា។

មុខវិជ្ជានេះលើកឡើងផងដែរពីសារៈសំខាន់នៃការប្រើប្រាស់កុំព្យូទ័រ ការបញ្ចូលបច្ចេកវិទ្យាកុំព្យូទ័រក្នុងការសិក្សា ទ្រឹស្តីនៃការរៀន ឬគម្រោងធ្វើបទបង្ហាញដោយប្រើបច្ចេកវិទ្យា និងការប្រើប្រាស់បទបង្ហាញ ដោយប្រើប្រាស់កម្មវិធីកុំព្យូទ័រដែលពាក់ព័ន្ធ។

## MEA 524 ការអភិវឌ្ឍកម្មវិធីសិក្សា

ការអភិវឌ្ឍកម្មវិធីសិក្សានៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សាត្រូវបានលើកយកមកពិភាក្សានៅក្នុងមុខវិជ្ជានេះ ដោយផ្តោតជាសំខាន់លើការរៀបចំកម្មវិធីសិក្សា ការអភិវឌ្ឍមុខវិជ្ជានីមួយៗ និងទំនាក់ទំនងរវាងបេសកកម្ម កម្មវត្ថុ និងលទ្ធផលសិក្សាទាំងនៅបឋមសិក្សា និងមធ្យមសិក្សា។ មុខវិជ្ជានេះនឹង៖

ក- វិភាគបញ្ហា និងនិន្នាការនានាសម្រាប់រៀបចំកម្មវិធីសិក្សា

ខ-វាយតម្លៃផលប៉ះពាល់ និងភ្នាក់ងារត្រួតពិនិត្យ លើគុណភាព នៃការរៀបចំកម្មវិធីសិក្សា

គ-ពិពណ៌នាពីសារៈសំខាន់ នៃទ្រឹស្តីក្នុងការធ្វើផែនការ និងការរៀបចំកម្មវិធីសិក្សា

ឃ-វិភាគទៅលើជំនឿ និងគុណតម្លៃ នៃការអប់រំជាមូលដ្ឋាន ព្រមទាំងផលប៉ះពាល់

ង-ពិពណ៌នាទ្រឹស្តីនៃការសិក្សាផ្សេងៗ និងការជះឥទ្ធិពលលើការធ្វើផែនការ និងការរៀបចំកម្មវិធីសិក្សា ។

## MEA 525 ការគ្រប់គ្រងសម្ភារៈ និងថវិកាវិស័យអប់រំ

លំនាំនៃការរៀបចំ ការវិភាគ និងការត្រួតពិនិត្យថវិកា គឺមានសារៈសំខាន់ណាស់សម្រាប់ធ្វើចរាចរហិរញ្ញវត្ថុរបស់ស្ថាប័ន អង្គភាព ឬសេវាកម្មណាមួយ ។ បញ្ញត្តិនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ក៏ដូចជាគោលការណ៍សេដ្ឋកិច្ចជាមូលដ្ឋាន ត្រូវបានយកមកអនុវត្ត។ មុខវិជ្ជានេះ នឹងផ្តោតសំខាន់លើ៖

ក-ការរៀបចំ និងត្រួតពិនិត្យថវិកា ដូចជាការវិភាគលើការប្រែប្រួលថវិកា និងយុទ្ធសាស្ត្រនានាសម្រាប់ដោះស្រាយនូវការប្រែប្រួលទាំងនោះ។ បង្កើតយុទ្ធសាស្ត្រសម្រាប់ការត្រួតពិនិត្យថវិកា និងការបង្កើតថវិកាជាសមាសភាគមួយនៃការធ្វើផែនការអាជីវកម្ម។

ខ-ការវិភាគ ការអនុវត្តហិរញ្ញវត្ថុ មានដូចជា វាយតម្លៃការអនុវត្តហិរញ្ញវត្ថុរបស់ស្ថាប័ន ឬការធ្វើអាជីវកម្មណាមួយ ដោយប្រើប្រាស់តារាងតុល្យភាព របាយការណ៍ចំណូល ចំណាយ របាយការណ៍លំហូរសាច់ប្រាក់ និងសមាមាត្រហិរញ្ញវត្ថុ ។

## MEA 526 ការគ្រប់គ្រងធនធានមនុស្ស

មុខវិជ្ជានេះ ពិនិត្យពីតួនាទីរបស់អ្នកជំនាញខាងធនធានមនុស្ស ដែលជាដៃគូយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងស្ថាប័ន ឬអង្គភាពនានាក្នុងពេលបច្ចុប្បន្ន។ មុខងារសំខាន់ៗដូចជា ការតែងតាំង ការជ្រើសរើស ការអភិវឌ្ឍ ការវាយតម្លៃ សំណងឬការប៉ះប៉ូវ និងទំនាក់ទំនងពលកម្មត្រូវបានត្រួតពិនិត្យ។ ផលប៉ះពាល់នានានៃច្បាប់ និងបរិយាកាសសកល ត្រូវបានវាយតម្លៃ ហើយបញ្ហាថ្មីៗដូចជាការបណ្តុះបណ្តាល ការបំពារបំពានផ្លូវភេទ និងការកើនឡើងនៃប្រាក់ចំណូលត្រូវបានវិភាគ។ ជម្រើសរបស់និយោជកក្នុងការអនុវត្តដ៏ល្អបំផុតត្រូវបានលើកមកពិភាក្សា។ លើសពីនេះទៅទៀត មុខវិជ្ជានេះក្តោបលើនីតិកម្ម ការវិភាគការងារ និងការរៀបចំផែនការធនធានមនុស្សដោយផ្តោតលើការផ្តល់បុគ្គលិកឱ្យស្ថាប័ន ឬអង្គភាពមួយឱ្យត្រូវនឹងប្រភេទ និងចំនួននៃនិយោជិតដែលខ្លួនត្រូវការនៅពេលណាមួយ។ ប្រធានបទនានាអាចរួមបញ្ចូលការណែនាំ និងតម្រង់ទិសបុគ្គលិកថ្មី ការអប់រំសម្រាប់អ្នកប្រតិបត្តិកម្រិតខ្ពស់ កម្មវិធីការអភិវឌ្ឍអាជីពដើម្បីបង្កើនការងារជាក្រុម ការអភិវឌ្ឍស្ថាប័ន ឬអង្គភាពក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរ សំណង និងដំណើរការលើកិច្ចព្រមព្រៀងតម្លៃ។

## MEA 527 ការពិនិត្យតាមដាន និងវាយតម្លៃអប់រំ

មុខវិជ្ជានេះ មានគោលបំណងត្រួតពិនិត្យទៅលើការបង្រៀន បច្ចេកទេសចាត់ចែង និងជំនាញផ្សេងៗទៀតដែលចាំបាច់ក្នុងការគ្រប់គ្រង និងវាយតម្លៃកម្មវិធីសិក្សា ហើយផ្តោតទៅលើការពិនិត្យតាមដាន និងវាយតម្លៃពីរបៀបគ្រប់គ្រងបុគ្គលិក ការអភិវឌ្ឍកម្មវិធីសិក្សា ការកែលម្អការបង្រៀនតាមរយៈលទ្ធផលនៃការសិក្សា ការវាយតម្លៃជាដំណាក់ៗ ការវាយតម្លៃចុងក្រោយតាមស្តង់ដារ និងការអភិវឌ្ឍបុគ្គលិក។ អ្នកសិក្សាត្រូវបានរំពឹងទុកថាអាចបង្កើតទំនាក់ទំនងល្អជាមួយបុគ្គលិក និងសហាគមន៍ ដូចជាការអភិវឌ្ឍយន្តការវាយតម្លៃសិស្ស ជួយបុគ្គលិកក្នុងការវាយតម្លៃការសិក្សា បង្កើនគុណភាពបង្រៀនឱ្យមានប្រសិទ្ធ

ភាព និងជំរុញឱ្យមានបរិយាកាសសិក្សាល្អក្នុងសាលារៀន។ មុខវិជ្ជានេះ នឹងគ្របដណ្តប់ផងដែរពីទស្សនៈវិស័យក្នុងការត្រួតពិនិត្យ និងវាយតម្លៃ។ ទស្សនៈវិស័យសំខាន់ៗទាំងនោះរួមមាន ការពិនិត្យតាមដានជាអ្វី ការវាយតម្លៃជាអ្វី គោលបំណងនៃការពិនិត្យតាមដាននិងការវាយតម្លៃ ទម្រង់នៃការពិនិត្យតាមដាននិងវាយតម្លៃ ការអនុវត្តការពិនិត្យតាមដាននិងវាយតម្លៃ និងលក្ខណៈនៃការពិនិត្យតាមដាននិងវាយតម្លៃ។ អ្នកសិក្សាត្រូវបានគេជំរុញឱ្យពិភាក្សាទៅលើប្រធានបទដូចជាវិធីពិនិត្យតាមដាន លំនាំធ្វើផែនការវាយតម្លៃ និងដំណាក់កាលនៃការវាយតម្លៃ។

**MEA 530 ការគ្រប់គ្រងការបំពេញការងារក្នុងសាលា**

មុខវិជ្ជានេះ បង្កើតឡើងសម្រាប់គណៈគ្រប់គ្រងសាលា និងមន្ត្រីទទួលបន្ទុកបុគ្គលិក ដែលជាអ្នកទទួលខុសត្រូវលើការគ្រប់គ្រង និងចាត់ចែងការងារនេះ។ គោលបំណងសំខាន់ គឺលើកកម្ពស់ការយល់ដឹងរបស់អ្នកសិក្សាឱ្យកាន់តែស៊ីជម្រៅពីសុវត្ថិភាពសាលាដោយបំប៉ននូវជំនាញសំខាន់ៗ និងជំរុញឱ្យបង្កើតផែនការគ្រប់គ្រងវិបត្តិទាំងឡាយដែលកើតមាននៅក្នុងសាលា។ អ្នកសិក្សានឹងស្វែងរកជំនាញដោះស្រាយបញ្ហាយ៉ាងមានប្រសិទ្ធភាព ដូចជាការបង្កើតវប្បធម៌ធ្វើសកម្មភាព បង្កើតជំហានវាយតម្លៃសកម្មភាព ធ្វើផែនការត្រួតពិនិត្យប្រចាំឆ្នាំ ប្រើប្រាស់កម្រងព័ត៌មានសម្រាប់ប្រមូល និងចងក្រងទុកជាភស្តុតាង ការរៀបចំវគ្គបណ្តុះបណ្តាល និងការធ្វើផែនការសកម្មភាពទៅអនាគត។

**MEA 531 ការគ្រប់គ្រងរដ្ឋបាលអប់រំនៅគ្រឹះស្ថានសិក្សាឯកជន**

មុខវិជ្ជានេះ នឹងពិភាក្សាគ្របដណ្តប់ទៅលើការបង្កើតប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចក៏ដូចជាយន្តការនៃការអនុវត្តរបស់គ្រឹះស្ថានសិក្សាឯកជន។ អ្នកសិក្សាត្រូវបានជំរុញឱ្យពិភាក្សាលើប្រធានបទដែលទាក់ទងទៅនឹងសាលាឯកជនរួមមានរចនាសម្ព័ន្ធ ធនធានមនុស្ស សិទ្ធិអំណាច គោលនយោបាយ ប្រសិទ្ធភាព គុណភាព សេចក្តីសម្រេច ទំនាក់ទំនង ភាពជាអ្នកដឹកនាំ និងបរិយាកាសវប្បធម៌ក្នុង និងក្រៅសាលា។

**MEA 599 និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

អ្នកសិក្សា នឹងត្រូវធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទដែលពាក់ព័ន្ធនឹងកំណែទម្រង់វិស័យអប់រំ និងត្រូវតែសរសេរនិក្ខេបបទស្រាវជ្រាវ។ ការត្រួតពិនិត្យជាប្រចាំត្រូវបានរៀបចំឡើង។ ដូចបានលើកឡើងរួចមកហើយ អ្នកសិក្សាគួរតែយល់ដឹងពីព័ត៌មានដូចខាងក្រោមមុនពេលសរសេរនិក្ខេបបទ៖

- ~~និក្ខេបបទ ឬរបាយការណ៍ស្រាវជ្រាវ អ្នកសិក្សាត្រូវគេរំពឹងថា បានរៀនចប់មុខវិជ្ជា~~ ចំនួន៤២ ក្រេឌីតជាមួយនឹងមធ្យមពិន្ទុ(GPA)យ៉ាងតិច ២.៣៣

- ចំពោះប្រធានបទ និងគោលគំនិតសំខាន់ៗនៃការស្រាវជ្រាវ ត្រូវទទួលការឯកភាពពីសាស្ត្រាចារ្យត្រួតពិនិត្យជាមុន
- ការប្រមូលព័ត៌មានសម្រាប់សរសេរនិក្ខេបបទ អ្នកសិក្សាម្នាក់ៗត្រូវធានាថា របាយការណ៍សិក្សាស្រាវជ្រាវ ឬនិក្ខេបបទរបស់ខ្លួនត្រូវសរសេរឡើងជាបន្តបន្ទាប់ជាមួយការណែនាំ និងការកែលំអពីសាស្ត្រាចារ្យត្រួតពិនិត្យ
- សេចក្តីព្រាងនៃនិក្ខេបបទត្រូវដាក់ជូនគណៈកម្មការកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដើម្បីធ្វើការវាយតម្លៃ ណែនាំ និងលើកជាសំណូមពរសម្រាប់កែលម្អក្រោយពីទទួលបានការឯកភាពពីគណៈកម្មការវាយតម្លៃនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ ការការពារ ឬការធ្វើបទបង្ហាញនិក្ខេបបទនោះនឹងត្រូវបានរៀបចំឡើងសម្រាប់អ្នកសិក្សាម្នាក់ៗ។

## ៧. លក្ខណសម្បត្តិរបស់សាស្ត្រាចារ្យ និងសមាជិកមហាវិទ្យាល័យ

លក្ខខណ្ឌជ្រើសរើសសាស្ត្រាចារ្យ សម្រាប់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មានដូចខាងក្រោម៖

- មានសញ្ញាបត្របណ្ឌិតជំនាញដែលទាក់ទងទៅនឹងមុខវិជ្ជាដែលត្រូវបង្រៀន ហើយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។
- មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ជំនាញ ដែលទាក់ទងទៅនឹងមុខវិជ្ជាដែលត្រូវបង្រៀន ហើយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា និងមានបទពិសោធយ៉ាងតិច៣ ឆ្នាំ ក្នុងការបង្រៀន ឬមានតួនាទីទាក់ទងមុខវិជ្ជាបង្រៀន។
- មានបទពិសោធច្រើនឆ្នាំ (១០ ឆ្នាំ) ក្នុងផ្នែកអប់រំ ផ្នែកគ្រប់គ្រង ហិរញ្ញវត្ថុ និងភាពជាអ្នកដឹកនាំ ។
- មានសមត្ថភាពល្អប្រសើរក្នុងការប្រើប្រាស់ភាសាអង់គ្លេសទាំងសរសេរ និងនិយាយ ។
- មានការប្តេជ្ញាចិត្តខ្ពស់ និងអាចធ្វើបាននូវ ៖

  - ការរៀបចំកិច្ចតែងការបង្រៀនទៅតាមការងារដែលបានកំណត់
  - ការអភិវឌ្ឍផែនការបង្រៀន និងរចនាសម្ព័ន្ធ ដែលគោរពតាមគោលការណ៍កម្មវិធី
  -ការផ្តល់ព័ត៌មានសម្រាប់អ្នកសិក្សា ដោយយោងតាមប្រព័ន្ធកម្មវិធីសិក្សា ដូចជាការងារស្រាវជ្រាវ វាយតម្លៃ និងលទ្ធផលរំពឹងទុក
  - ការវាយតម្លៃពីចំណុចខ្លាំង និងចំណុចខ្សោយរបស់អ្នកសិក្សាបានយ៉ាងត្រឹមត្រូវ
  - ការផ្តល់ពិន្ទុដល់អ្នកសិក្សាតាមគោលការណ៍ដែលបានកំណត់
  -សាស្ត្រាចារ្យ ត្រូវបង្ហាញសមត្ថភាពខ្ពស់ ក្នុងការបង្រៀនប្រកបដោយប្រសិទ្ធភាព និងគុណភាព

-គុណភាពល្អប្រសើរក្នុងការបង្រៀនរួមមាន ភាពស្ទាត់ជំនាញ ចំណាប់ចំណូលចិត្ត និង ភាពរួសរាយ។

- មានអាកប្បកិរិយាសមរម្យ។

## ៨. លក្ខខណ្ឌនៃការជ្រើសរើសបេក្ខជន

- បេក្ខជនត្រូវមានបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល
- បេក្ខជនទាំងពីរភេទជាបុគ្គលិកអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បេក្ខជនទាំងពីរភេទត្រូវឆ្លងកាត់ការប្រឡងជ្រើសរើស។

## ៩. ពេលវេលាសិក្សា

### ៩.១ វគ្គសិក្សាក្រៅម៉ោងធ្វើការ (លក្ខណៈពិសេស)

| ថ្នាក់ប្រចាំថ្ងៃ | | | | | |
|---|---|---|---|---|---|
| ម៉ោងសិក្សា | ចន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ |
| ១៧:៣០ ១៩:00 | [redacted] | | | | x |
| ១៩:00 – ២០:៣០ | | | | | x |
| | | | | | |

### ៩.២ វគ្គសិក្សានៅចុងសប្តាហ៍ (វគ្គសិក្សាទៀងទាត់)

| ថ្នាក់ចុងសប្តាហ៍ | | | |
|---|---|---|---|
| ពេលវេលា | ម៉ោងសិក្សា | សៅរ៍ | អាទិត្យ |
| ព្រឹក | ៨:00 – ១១:00 | | x |
| ល្ងាច | ១៤:00 – ១៧:00 | x | |